ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស

លេខ:...........✓...................

# សេចក្តីប្រកាសព័ត៌មាន

------------

អនុគណៈកម្មការខ្លឹមសារ និងឯកសារ នៃគណៈកម្មការអន្តរក្រសួងដើម្បីទទួលរៀបចំធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ាន និងកិច្ចប្រជុំពាក់ព័ន្ធ ឆ្នាំ២០២២ នឹងរៀបចំនូវសន្និសីទសន្តិសុខនយោបាយវេទិកាតំបន់អាស៊ាន លើកទី១៩ (19th ASPC) នៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២២ តាមរយៈប្រព័ន្ធវីដេអូ ក្រោមមូលបទ “**សាមគ្គីភាពដើម្បីសន្តិសុខប្រកបដោយភាពសុខដុម**”។ សន្និសីទថ្នាក់តំបន់កម្រិតខ្ពស់នេះនឹងដឹកនាំដោយ **ឯកឧត្តម នាយឧត្តមសេនីយ៍ ណឹម សុវត្ថិ** ទីប្រឹក្សាពិសេស **សម្តេចពិជ័យសេនា ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការពារជាតិ អគ្គនាយក អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស ក្រសួងការពារជាតិ ដោយមានការចូលរួមពីសំណាក់មន្ត្រីជាន់ខ្ពស់ផ្នែកគោលនយោបាយសន្តិសុខ និងការពារជាតិ នៃបណ្តាប្រទេសជាសមាជិកវេទិកាតំបន់អាស៊ានចំនួន ២៧ប្រទេស រួមទាំងតំណាងលេខាធិការដ្ឋានអាស៊ាន។

ក្នុងអំឡុងនៃសន្និសីទ បណ្តាប្រទេសជាសមាជិកវេទិកាតំបន់អាស៊ាន នឹងធ្វើការផ្លាស់ប្តូរទស្សនៈស្តីពីបញ្ហាតំបន់ និងអន្តរជាតិ ដោយផ្តោតជាពិសេសលើ (១) ការវិវត្តន៍នៃស្ថានការណ៍សន្តិសុខ និងការពារជាតិនៅក្នុងតំបន់ និងអន្តរជាតិ (២) ការរិះរកវិធានការជំរុញកិច្ចសហប្រតិបត្តិការការពារជាតិតំបន់ក្រោយជំងឺកូវីដ១៩ និង (៣) ការលើកកម្ពស់វិធានការកសាងទំនុកចិត្ត និងការពង្រឹងសាមគ្គីភាព និងកិច្ចសហប្រតិបត្តិការការពារជាតិ ក្នុងចំណោមប្រទេសជាសមាជិកវេទិកាតំបន់អាស៊ានឆ្ពោះទៅសន្តិសុខប្រកបដោយភាពសុខដុម។

សន្និសីទសន្តិសុខនយោបាយវេទិកាតំបន់អាស៊ាន គឺជាវេទិកាដ៏មានសារសំខាន់មួយសម្រាប់កិច្ចសន្ទនាកម្រិតខ្ពស់ពាក់ព័ន្ធបញ្ហាសន្តិសុខ និងការពារជាតិក្នុងតំបន់ និងអន្តរជាតិ និងដើម្បីលើកកម្ពស់ភាពជឿជាក់ និងការយោគយល់ទៅវិញទៅមកក្នុងបណ្តាប្រទេសចូលរួម ក្នុងគោលបំណងពង្រឹងសន្តិភាព ស្ថិរភាព និងសន្តិសុខក្នុងតំបន់ប្រកបដោយចីរភាព។

ភាពជាម្ចាស់ផ្ទះសន្និសីទសន្តិសុខនយោបាយវេទិកាតំបន់អាស៊ានលើកទី១៩ សរបញ្ជាក់អំពីការប្តេជ្ញាចិត្តរបស់ក្រសួងការពារជាតិកម្ពុជា ក្នុងនាមជាម្ចាស់ផ្ទះកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ាន (ADMM) និងកិច្ចប្រជុំពាក់ព័ន្ធក្នុងឆ្នាំ២០២២ ដើម្បីជំរុញសាមគ្គីភាពអាស៊ាន រួមគ្នាដោះស្រាយបញ្ហាប្រឈមសន្តិសុខតំបន់ទាំងក្នុងពេលបច្ចុប្បន្ន និងទៅអនាគត ស្របតាមមូលបទ “**សាមគ្គីភាពដើម្បីសន្តិសុខប្រកបដោយភាពសុខដុម**”។

ថ្ងៃព្រហស្បតិ៍ ៣កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២២